# ប្រភេទផ្សេងៗនៃសហគ្រិន

| | | |
|---|---|---|
| ១ | សហគ្រិន<br>អ. entrepreneur | រូបវន្តបុគ្គលមានសមត្ថភាព ឱកាស និងឆន្ទៈ ក្នុងការបង្កើតចាត់ចែង និងគ្រប់គ្រងអាជីវកម្មណាមួយដែលប្រកបដោយនវានុវត្តន៍និងអាចមានហានិភ័យ ក្នុងគោលបំណងទទួលបានប្រាក់ចំណេញនិងធានាបាននូវសុខុមាលភាព សង្គម។ |
| ២ | សហគ្រិនខ្មីឃ្មាត<br>អ.hustler entrepreneur | សហគ្រិនមួយប្រភេទដែលមានឆន្ទៈខិតខំធ្វើការនិងការប្រឹងប្រែងឥតឈប់ឈរសំដៅពង្រីកអាជីវកម្មពីតូចទៅធំ ដោយបប្រើការព្យាយាមជាងមូលធន។ |
| ៣ | សហគ្រិនអ្នកទិញ<br>អ. buyer entrepreneur | សហគ្រិនមួយប្រភេទផ្តោតលើការទិញយកអាជីវកម្មដែលមានស្រាប់មកគ្រប់គ្រងនិងអភិវឌ្ឍ។ |
| ៤ | សហគ្រិនជាតិពន្ធុ<br>អ. ethnic entrepreneur | សហគ្រិនមួយប្រភេទដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមជនជាតិដូចគ្នា។ ទំនិញឬសេវាដែលត្រូវបានផលិតឬដាក់លក់ភាគច្រើនបង្ហាញនូវអត្តសញ្ញាណជាតិរបស់សហគ្រិននោះ ដើម្បីបំពេញតម្រូវការសង្គម សេដ្ឋកិច្ចនៅកន្លែងដែលមិនមែនជាទឹកដីកំណើត។ |
| ៥ | សហគ្រិនជនជាតិភាគតិច<br>អ. minority entrepreneur | សហគ្រិនមួយប្រភេទដែលជាជនជាតិភាគតិច កាន់កាប់ភាគហ៊ុនយ៉ាងតិច ៥១% រៀបចំ ដាក់ឱ្យដំណើរការ និងគ្រប់គ្រងសហគ្រាសមួយឬច្រើន។ |
| ៦ | សហគ្រិនអន្តោប្រវេសន៍<br>អ. immigrant entrepreneur | សហគ្រិនមួយប្រភេទដែលបានចាកចេញពីប្រទេសកំណើតទៅប្រកបអាជីវកម្មនៅក្នុងប្រទេសមួយផ្សេងទៀត។ |
| ៧ | សហគ្រិនស្ត្រី អ. woman entrepreneur | សហគ្រិនមួយប្រភេទដែលជាស្ត្រីមានសមត្ថភាព ឱកាស និងឆន្ទៈ ក្នុងការបង្កើត ចាត់ចែង និងគ្រប់គ្រងអាជីវកម្មណាមួយដែប្រកបដោយនវានុវត្តន៍និងអាចមានហានិភ័យ ក្នុងគោលបំណងទទួលបានប្រាក់ចំណេញនិងធានាបាននូវសុខមាលភាពសង្គម។ |
| ៨ | សហគ្រិនអ្នកស្រាវជ្រាវ អ. researcher entrepreneur | សហគ្រិនមួយប្រភេទដែលប្រកបអាជីវកម្មផ្អែកលើព្រឹត្តិការណ៍ជាក់ស្តែងនិងទិន្នន័យស្រាវជ្រាវវិទ្យាសាស្ត្រជាក់លាក់។ សហគ្រិននេះជឿជាក់ថា ចំណេះដឹង បទពិសោធ និងការរៀបចំត្រឹមត្រូវអាចនឹងធ្វើឱ្យទទួលបានជោគជ័យ។ |

| | | |
|---|---|---|
| ៩ | សហគ្រិនចរកឌីជីថល អ. digital nomad entrepreneur | សហគ្រិនមួយប្រភេទដែលធ្វើអាជីវកម្មតាមអនឡាញ ដោយពួកគេអាចធ្វើការពីគ្រប់ទីកន្លែង។ |
| ១០ | សហគ្រិននវានុវត្តន៍ អ. innovative entrepreneurs | សហគ្រិនមួយប្រភេទដែលបង្កើតទំនិញឬសេវាថ្មី បង្ហាញនូវវិធីសាស្ត្រថ្មីនៃការផលិត ឱកាសទីផ្សារថ្មី និងការរៀបចំរចនាសម្ព័ន្ធថ្មីរបស់សហគ្រាស។ កិច្ចការរបស់សហគ្រិនប្រភេទនេះត្រូវធ្វើឱ្យមានកម្រិតនៃការអភិវឌ្ឍណាមួយ ហើយព្យាយាមធ្វើឱ្យមានការផ្លាស់ប្តូរនិងប្រសើរជាងមុន។ |
| ១១ | សហគ្រិនត្រាប់តាម អ. imitative entrepreneur | សហគ្រិនមួយប្រភេទដែលប្រកបអាជីវកម្មដោយផ្អែកលើម៉ូដែលអាជីវកម្មជោគជ័យដែលមានស្រាប់របស់អ្នកដទៃ ហើយកែសម្រួលឱ្យប្រសើរឡើងដើម្បីប្រកួតប្រជែង។ |
| ១២ | សហគ្រិនហ្វាបៀន/សហគ្រិនផាបៀន អ. Fabian entrepreneur | សហគ្រិនមួយប្រភេទដែលមានការប្រយ័ត្នប្រយែងនិងមិនងាយទទួលយកការប្រែប្រួលតាមស្ថានភាពទីផ្សារ។ បន្ទាប់ពីបានពិចារណាល្អិតល្អន់រួចមក សហគ្រិននេះរង់ចាំឱកាសល្អ សង្កេតមើលចំណុចខ្សោយរបស់គូប្រជែង ដើម្បីទទួលហានិភ័យកាន់តែទាប មុនពេលទទួលយកនវានុវត្តន៍។ |
| ១៣ | សហគ្រិនដ្រូន អ. drone entrepreneur | សហគ្រិនមួយប្រភេទដែលមិនងាយទទួលយកនវានុវត្តន៍ការប្រែប្រួលទីផ្សារ និងឱកាសថ្មីៗក្នុងដំណើរការអាជីវកម្ម ទោះបីជាដឹងថាអាជីវកម្មប្រឈមនឹងការខាតបង់ក៏ដោយ។ |